**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
Nation Religion King

**ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**
**Ministry of Industry, Mines and Energy**
លេខ :...៥១៥...ឧ.ស.ថ.រ.សកក(២៦)

# ប្រកាស
## ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាស្តង់ដារជាតិ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីស្តង់ដារកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃវិទ្យាស្ថានស្តង់ដារកម្ពុជា
- យោងតាមការចាំបាច់របស់ក្រសួង

## ស ម្រេ ច

**ប្រការ ១** : បង្កើតក្រុមប្រឹក្សាស្តង់ដារជាតិ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម ស៊ុយ សែម | តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ប្រធាន |
| ២- ឯកឧត្តម ពិង ស៊ីវឡាយ | ប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា | អនុប្រធាន អចិន្ត្រៃយ៍ |

Downloaded from http://www.khmerlaws.com

| | | |
|---|---|---|
| ៣- ឯកឧត្តម ឌិត ទីណា | តំណាងក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៤- ឯកឧត្តម ម៉ែន ស៊ីផាន់ | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៥- លោកឱសថបណ្ឌិត ហេង ប៊ុនគៀត | តំណាងក្រសួងសុខាភិបាល | អនុប្រធាន |
| ៦- ឯកឧត្តម ទិត ចន្ថា | តំណាងក្រសួងទេសចរណ៍ | សមាជិក |
| ៧- ឯកឧត្តម ឡៅ ហ៊ីម | តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៨- លោកបណ្ឌិត ហ៊ែល ចំរើន | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៩- លោកបណ្ឌិត យិត បុណ្ណា | តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១០- លោក ជា ស៊ីណា | តំណាងក្រសួងបរិស្ថាន | សមាជិក |
| ១១- លោក ឡុង ប៊ុណ្ណាស៊ីរីវត្ត | តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១២- លោក ហ៊ុយ ណាវ៉ា | តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១៣- លោកបណ្ឌិត ហាន វីរៈ | តំណាងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | សមាជិក |
| ១៤- លោកស្រីបណ្ឌិត សៀង ហ៊ុយ | តំណាងរាជបណ្ឌិត្យសភាកម្ពុជា | សមាជិក |
| ១៥- លោក ឡុង ឡាយ | តំណាងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ១៦- លោកសាស្ត្រាចារ្យ អ៊ុំង ចាន់នី | តំណាងសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល | សមាជិក |
| ១៧- លោក សុក គន្ធី | តំណាងសាកលវិទ្យាល័យភូមិន្ទកសិកម្ម | សមាជិក |
| ១៨- លោក ឡុញ គីមអៀន | តំណាងសភាពាណិជ្ជកម្មកម្ពុជា | សមាជិក |
| ១៩- លោក ហេង ហ៊ាង | តំណាងសមាគមអ្នកផលិត | សមាជិក |
| ២០- លោក ស៊ឹល វីរនេត្រ | តំណាងសមាគមអ្នកប្រើប្រាស់ | សមាជិក |

**ប្រការ ២** : ក្រុមប្រឹក្សាស្តង់ដារជាតិ មានភារកិច្ចដូចតទៅ:

- សម្រេចយល់ព្រម កែសម្រួល ឬលុបចោលស្តង់ដារជាតិណាមួយ
- សម្រេចយល់ព្រម កែសម្រួល ឬលុបចោលសញ្ញាស្តង់ដារជាតិណាមួយ
- កំណត់អំពីស្តង់ដារស្ម័គ្រចិត្ត ឬស្តង់ដារបញ្ជា ឬសញ្ញាស្តង់ដារ
- ជូនយោបល់ដល់រដ្ឋមន្ត្រីអំពីអាទិភាព និងគោលនយោបាយនៃស្តង់ដារូបនីយកម្ម កម្មវិធី ផែនការ គម្រោង និងសកម្មភាពនានា ដើម្បីធានាឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត

Downloaded from http://www.khmerlaws.com

- ជូនយោបល់និងលើកអនុសាសន៍ជូនរដ្ឋមន្ត្រី អំពីការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃស្តង់ដារ សម្រាប់ផលិតផល ដំណើរការអនុវត្ត ការធ្វើតេស្ត និងសេវាកម្ម និងសម្រេចយល់ព្រមលើកម្មវិធី ផែនការ គម្រោង និងសកម្មភាពនានា សំដៅជំរុញប្រសិទ្ធភាព និងការអភិវឌ្ឍឧស្សាហកម្ម និងសម្រាប់ការពារអ្នកប្រើប្រាស់តាមរយៈសកម្មភាពស្តង់ដារូបនីយកម្ម
- ណែនាំវិទ្យាស្ថានអំពីលក្ខណៈវិនិច្ឆ័យ និងនីតិវិធីដែលទាក់ទិនដល់ការរៀបចំ ការសម្រេចយល់ព្រម ការទទួលយក និងការជ្រើសរើសស្តង់ដារ
- រៀបចំបទបញ្ជាផ្ទៃក្នុង សម្រាប់ការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សា
- បំពេញមុខងារដទៃទៀតទៅតាមការកំណត់ ឬតាមការប្រគល់សិទ្ធិរបស់រដ្ឋមន្ត្រី។

**ប្រការ ៣ :**

សមាជិកក្រុមប្រឹក្សាស្តង់ដារជាតិត្រូវចូលរួមប្រជុំឱ្យបានទៀងទាត់តាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាស្តង់ដារជាតិ។ សម័យប្រជុំក្រុមប្រឹក្សាអាចប្រព្រឹត្តទៅបាន លុះត្រាតែមានកូរ៉ុមចំនួនលើសពីពាក់កណ្តាលនៃសមាជិកសរុប។ រាល់សេចក្តីសម្រេចណាមួយរបស់ក្រុមប្រឹក្សា ត្រូវប្រព្រឹត្តទៅដោយមតិភាគច្រើន ពីរភាគបីនៃចំនួនសមាជិកវត្តមានក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា លើកលែងតែការពិនិត្យសម្រេចឬការកែសម្រួលស្តង់ដារជាតិ ដែលត្រូវអនុម័តតាមមតិបីភាគបួននៃចំនួនសមាជិកចូលរួមប្រជុំ។ នៅពេលប្រធានអវត្តមាន ក្រុមប្រឹក្សាស្តង់ដារជាតិអាចធ្វើការប្រជុំទៅបាន ក្រោមការដឹកនាំរបស់អនុប្រធានក្រុមប្រឹក្សា ឬ សមាជិកតំណាងណាម្នាក់ ដែលបានទទួលការប្រគល់សិទ្ធិពីប្រធាន។

**ប្រការ ៤ :** ក្រុមប្រឹក្សាស្តង់ដារជាតិអាចបង្កើតគណៈកម្មការបច្ចេកទេសស្តង់ដារ អនុគណៈកម្មការបច្ចេកទេសស្តង់ដារ ឬក្រុមការងារស្តង់ដារទៅតាមវិស័យនិមួយៗបាន ដើម្បីជួយបំពេញមុខងារនិងភារកិច្ច ឬសំរាប់គោលបំណងផ្សេងទៀត ដែលកើតឡើងឬដែលទាក់ទិនដល់មុខងារនិងភារកិច្ចរបស់ខ្លួន។

**ប្រការ ៥ :** ក្រុមប្រឹក្សាស្តង់ដារជាតិអាចធ្វើការកែសម្រួលឬលុបចោលសេចក្តីសម្រេចណាមួយ ដែលគណៈកម្មការបច្ចេកទេសស្តង់ដារបានអនុម័ត។

**ប្រការ ៦ :** ក្នុងករណីសមាជិកក្រុមប្រឹក្សាស្តង់ដារជាតិម្នាក់អវត្តមាននៅក្នុងកិច្ចប្រជុំ នោះមានន័យថា សមាជិករូបនោះបានឯកភាពទៅលើអ្វីដែលកិច្ចប្រជុំអនុម័ត។

Downloaded from http://www.khmerlaws.com

**ប្រការ ៧** : ប្រធានក្រុមប្រឹក្សាស្តង់ដារជាតិ ត្រូវទទួលខុសត្រូវលើសកម្មភាពស្តង់ដារូបនីយកម្ម ចំពោះមុខរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ ៨** : ប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា និងឯកឧត្តម អស់លោក លោកស្រី ដែលមានឈ្មោះក្នុងប្រការ ១ មានភារកិច្ចអនុវត្តក្របខ័ណ្ឌភារកិច្ចរៀងៗខ្លួនតាមប្រកាសនេះ ។

**ប្រការ ៩** : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ[illegible] ឆ្នាំ២០០៩

ស៊ុយ សែម

<u>ចម្លងជូន:</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- គ្រប់ក្រសួង-ស្ថាប័ន ដូចប្រការ ១
- ដូចប្រការ ៨
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

Downloaded from http://www.khmerlaws.com